MAINE IMMIGRANTS' RIGHTS COALITION

# វ៉ាក់សាំង COVID-19៖ សំណួរដែលសួរញឹកញាប់

## តើការចាក់វ៉ាក់សាំងការពារ COVID-19 មានអត្ថប្រយោជន៍អ្វីខ្លះ?

ការចាក់វ៉ាក់សាំងអាចការពារអ្នកពីការឆ្លងជំងឺ COVID-19 និងអាចការពារក្រុមគ្រួសារ និងសហគមន៍របស់អ្នកពីការឈឺបានដែរ។
ការចាក់វ៉ាក់សាំងគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការបញ្ឈប់ការរាតត្បាតជំងឺ COVID-19 និងដើម្បីឲ្យសហគមន៍របស់យើងត្រឡប់ទៅប្រក្រតីភាពវិញ។

## តើវ៉ាក់សាំង COVID-19 បច្ចុប្បន្នមានវ៉ាក់សាំងអ្វីខ្លះ?

ឥឡូវនេះមានវ៉ាក់សាំងពីរប្រភេទដែលត្រូវបានអនុម័តៈ

- **វ៉ាក់សាំង COVID-19 Pfizer BioNTech**
- **វ៉ាក់សាំង COVID-19 Moderna**

វ៉ាក់សាំងទាំងពីរនេះមានប្រសិទ្ធភាពណាស់ ហើយមានការសិក្សា និងការស្រាវជ្រាវដើម្បីធ្វើឱ្យប្រាកដថា វាមានសុវត្ថិភាពសម្រាប់សាធារណជន។

## តើអ្នកណាគួរចាក់វ៉ាក់សាំង?

បុគ្គលដែលមានអាយុចាប់ពី 16 ឆ្នាំឡើងអាចវ៉ាក់សាំង Pfizer BioNTech និងបុគ្គលដែលមានអាយុចាប់ពី 18 ឆ្នាំឡើងអាចចាក់វ៉ាក់សាំង Modern។

## តើខ្ញុំអាចចាក់វ៉ាក់សាំងនៅពេលណា?

រដ្ឋ Maine កំពុងប្រើវិធីសាស្ត្រក្នុងការចាក់វ៉ាក់សាំងជាដំណាក់កាល។ ឥឡូវនេះ យើងស្ថិតនៅក្នុងដំណាក់កាលទីមួយ។ ក្នុងដំណាក់កាលនេះ បុគ្គលិកថែទាំសុខភាព អ្នកឆ្លើយតបគ្រាអាសន្ន អ្នកនៅក្នុងមណ្ឌលជំនួយការរស់នៅ និងមនុស្សដែលមានអាយុលើសពី 70 ឆ្នាំកំពុងទទួលការចាក់វ៉ាក់សាំង។ មនុស្សដែលមានអាយុចន្លោះពី 65 ទៅ 69 ឆ្នាំ និងមនុស្សពេញវ័យដែលមានលក្ខខណ្ឌវេជ្ជសាស្ត្រប្រឈមជាមួយហានិភ័យខ្ពស់នឹងទទួលបានការចាក់វ៉ាក់សាំងនៅដំណាក់កាលបន្ទាប់។ វ៉ាក់សាំងសម្រាប់មនុស្សទូទៅអាចមាននៅរដូវក្តៅឆ្នាំ 2021។

## តើវ៉ាក់សាំងនេះត្រូវបានផ្តល់ឱ្យយ៉ាងដូចម្តេច?

វ៉ាក់សាំងទាំងពីរត្រូវបានផ្តល់ឱ្យអ្នកដោយចាក់ចូលសាច់ដុំ ហើយត្រូវការចាក់ពីរដូស។ ចំពោះវ៉ាក់សាំង Pfizer BioNTech ដូសទាំងនេះត្រូវចាក់រយៈពេលពីរសប្តាហ៍ដាច់ពីគ្នា។ ចំពោះវ៉ាក់សាំង Moderna ដូសទាំងនេះត្រូវចាក់មួយខែដាច់ពីគ្នា។

**ចង់ដឹងព័ត៌មានបន្ថែមអំពីវ៉ាក់សាំង COVID-19 មែនទេ?**
**សូមផ្ញើសំណួររបស់អ្នកតាមអ៊ីមែលទៅកាន់ C19vaccine.MECDC@maine.gov**

ព័ត៌មានដែលបានដកស្រង់ចេញពី CDC រដ្ឋ Maine៖ https://www.maine.gov/covid19/vaccines/public-faq

MAINE IMMIGRANTS' RIGHTS COALITION

**តើខ្ញុំគួរប្រាប់អ្វីខ្លះដល់អ្នកផ្តល់វ៉ាក់សាំងរបស់ខ្ញុំមុនពេលខ្ញុំចាក់វ៉ាក់សាំងនេះ?**

អ្នកគួរតែប្រាប់អ្នកផ្តល់វ៉ាក់សាំងរបស់អ្នកអំពី **លក្ខខណ្ឌវេជ្ជសាស្ត្រណាមួយ** ដែល អ្នកមាន ហើយប្រសិនបើអ្នក៖

- មានប្រតិកម្មអាលែកហ្ស៊ីណាមួយ
- មានគ្រុនក្តៅ
- មានវិបត្តិបង្កឲ្យធ្លាក់ឈាម ឬកំពុងលេបថ្នាំពង្រាវឈាម
- មានប្រព័ន្ធការពារភាពស៊ាំចុះខ្សោយ ឬកំពុងប្រើថ្នាំដែលប៉ះពាល់ដល់ប្រព័ន្ធភាពស៊ាំរបស់អ្នក
- មានផ្ទៃពោះ ឬមានគម្រោងមានផ្ទៃពោះ
- កំពុងបំបៅដោះកូន
- បានចាក់សាំង COVID-19 ប្រភេទមួយទៀត

**តើមានផលរំខានណាមួយទេ? តើខ្ញុំគួរធ្វើដូចម្តេច ប្រសិនបើខ្ញុំមានផលរំខានទាំងនេះ?**

អ្នកអាចមានផលរំខានកម្រិតស្រាលខ្លះពីការចាក់វ៉ាក់សាំង។ នេះគឺជាប្រតិកម្មធម្មតា ហើយវានឹងបាត់ទៅវិញក្នុងរយៈពេលពីរបីថ្ងៃ។ ផលរំខានអាចមានដូចជារោគសញ្ញានៃជំងឺ COVID-19 (ឈឺសាច់ដុំ ឈឺក្បាល និងគ្រុនញាក់) និងទំនងមានច្រើនជាងនេះបន្ទាប់ពីចាក់ដូសលើកទីពីរ។ លទ្ធភាពនៃការមានផលរំខានធ្ងន់ធ្ងរគឺតិចណាស់។

**តើខ្ញុំអាចចាក់វ៉ាក់សាំងបានទេ ប្រសិនបើខ្ញុំមានផ្ទៃពោះ ឬកំពុងបំបៅដោះកូន?**

អ្នកគួរតែពិភាក្សាអំពីជម្រើសរបស់អ្នកជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ឬបុគ្គលិកសុខាភិបាលសហគមន៍។

**ខ្ញុំមានជំងឺ COVID-19 រួចហើយ តើខ្ញុំនៅតែគួរចាក់វ៉ាក់សាំងដែរឬទេ?**

ប្រសិនបើអ្នកធ្លាប់មានជំងឺ COVID-19 គេផ្តល់អនុសាសន៍ឱ្យអ្នកទៅចាក់វ៉ាក់សាំង។ អ្នកអាចចាក់វ៉ាក់សាំងនៅពេលណាមួយបន្ទាប់ពីអ្នកបានជាពីជំងឺ COVID-19។

**ខ្ញុំមានលក្ខណ្ឌវេជ្ជសាស្ត្រដែលមានស្រាប់ តើវ៉ាក់សាំងមានសុវត្ថិភាពសម្រាប់ខ្ញុំទេ?**

អ្នកគួរតែពិភាក្សាពីលក្ខខណ្ឌ ឬកង្វល់ណាមួយដែលអ្នកមានជាមួយអ្នកផ្តល់សេវាថែទាំសុខភាព ឬបុគ្គលិកសុខាភិបាលសហគមន៍របស់អ្នក ដើម្បីសម្រេចថាតើវ៉ាក់សាំងនេះសមស្របសម្រាប់អ្នកដែរឬទេ។

**តើវ៉ាក់សាំងនេះនឹងធ្វើឱ្យខ្ញុំកើតជំងឺ COVID-19 ដែរទេ?**

ទេ វ៉ាក់សាំងនេះនឹងមិនធ្វើឱ្យអ្នកកើតជំងឺ COVID-19 ទេ។

**ចង់ដឹងព័ត៌មានបន្ថែមអំពីវ៉ាក់សាំង COVID-19 មែនទេ?**
**សូមផ្ញើសំណួររបស់អ្នកតាមអ៊ីមែលទៅកាន់ C19vaccine.MECDC@maine.gov**

ព័ត៌មានដែលបានដកស្រង់ចេញពី CDC រដ្ឋ Maine៖ https://www.maine.gov/covid19/vaccines/public-faq

MAINE IMMIGRANTS' RIGHTS COALITION

**តើវ៉ាក់សាំងមានផ្ទុកអ្វីខ្លះ?**

វ៉ាក់សាំងទាំងពីរដូស **<u>មិនមានផ្ទុក</u>** ស៊ុត សារធាតុរក្សាគុណភាព ឬជ័រទេ។
អ្នកអាចរកឃើញបញ្ជីសមាសធាតុផ្សំនៅទីនេះ៖

- វ៉ាក់សាំង Pfizer BioNTech៖ https://www.fda.gov/media/144414/download
- វ៉ាក់សាំង Moderna៖ https://www.fda.gov/media/144638/download

**តើវ៉ាក់សាំងទាំងពីរដូសគួរតែមកពីក្រុមហ៊ុនផលិតតែមួយដែរទេ?**

បាទ/ចាស។ ដូសទីមួយ និងដូសទីពីរនៃវ៉ាក់សាំង **<u>ត្រូវតែ</u>** មកពីក្រុមហ៊ុនផលិតដូចគ្នា (វ៉ាក់សាំង Pfizer ឬ Moderna)។ អ្នក **<u>មិនអាច</u>** ចាក់ដូសមួយពីវ៉ាក់សាំងនីមួយៗបានទេ។

**បន្ទាប់ពីខ្ញុំបានចាក់វ៉ាក់សាំងពីរដូសរួចហើយ តើខ្ញុំនៅតែត្រូវពាក់ម៉ាស់ ហើយអនុវត្តការរក្សាគម្លាតសុវត្ថិភាពសង្គមដែរឬទេ?**

បាទ/ចាស ទោះបីអ្នកបានចាក់វ៉ាក់សាំងក៏ដោយ អ្នកគួរតែបន្តពាក់ម៉ាស់ ហើយចៀសវាងការប៉ះពាល់ជិតស្និទ្ធជាមួយអ្នកដទៃ។ មិនមានព័ត៌មានគ្រប់គ្រាន់នៅឡើយទេសម្រាប់ CDC រដ្ឋ Maine ដើម្បីបញ្ឈប់ការទាមទារឱ្យបុគ្គលម្នាក់ៗអនុវត្តតាមនីតិវិធីការពារសុវត្ថិភាពពីជំងឺ COVID-19។

## ចង់ដឹងព័ត៌មានបន្ថែមអំពីវ៉ាក់សាំង COVID-19 មែនទេ?

## សូមផ្ញើសំណួររបស់អ្នកតាមអ៊ីមែលទៅកាន់ C19vaccine.MECDC@maine.gov

ព័ត៌មានដែលបានដកស្រង់ចេញពី CDC រដ្ឋ Maine៖ https://www.maine.gov/covid19/vaccines/public-faq